វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា

ANZ Royal

# សង្ខេបចក្ខុវិស័យប្រទេសកម្ពុជា*

ឆ្នាំ២០១៣ លេខ ០៤

## អាទិភាពគោលនយោបាយទទួលបានពី សន្និសីទចក្ខុវិស័យប្រទេសកម្ពុជាឆ្នាំ២០១៣[១]

១. កែលំអ និងធ្វើពិពិធកម្មការផលិត និងផ្គត់ផ្គង់ថាមពល

- បន្តពង្រីកការផ្គត់ផ្គង់ថាមពលអគ្គិសនី ទៅដល់គ្រួសារនៅតាមជនបទ
- កែលំអរបៀបរៀបចំស្ថាប័ន និងការធានាសុវត្ថិភាពសម្រាប់ការកសាងទំនប់វារីអគ្គិសនី
- ធ្វើពិពិធកម្មធនធានថាមពលក្នុងស្រុក ដែលប្រើប្រាស់សម្រាប់ផលិតអគ្គិសនី ដូចជា ការប្តូរទៅប្រើត្បូងថ្ម និងថាមពលពន្លឺព្រះអាទិត្យ។

២. កែលំអ និងធ្វើពិពិធកម្មហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូនសម្រាប់ការនាំចេញ និងការប្រកួតប្រជែងផ្នែកពាណិជ្ជកម្ម

- ធ្វើកំណែទម្រង់សកម្មភាពដឹកជញ្ជូនតាមទន្លេ-ស្ទឹង និងពន្ធតាមផ្លូវទឹក ដើម្បីអភិវឌ្ឍផ្លូវទឹក និងកំពង់ផែតាមទន្លេ-ស្ទឹង
- អភិវឌ្ឍសមត្ថភាពផ្តល់សេវាគាំទ្រ (logistics) ដូចជា សេវាកម្មប្រកចូលតែមួយជាដើម ដើម្បីជួយប៉ះប៉ូវដល់ នីតិវិធីការិយាធិបតេយ្យដ៏យឺតយ៉ាវ និងមានចំណាយខ្ពស់
- បង្កើនសមត្ថភាពហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ដូចជា កំពង់ផែសមុទ្រ ផែស្ងួត ផ្លូវទឹក ស្ពាន ផ្លូវតាមជនបទ ផ្លូវថ្នល់ធំៗ និងផ្លូវដែក។

៣. ពង្រឹងយន្តការអន្តរក្រសួង ដើម្បីបង្កើនភាពជាដៃគូរវាងវិស័យសាធារណៈ-ឯកជន ក្នុងផ្នែកថាមពល និងដឹកជញ្ជូន

- ពង្រឹងអង្គភាពសម្របសម្រួល ដូចជា ភាពជាដៃគូវិស័យសាធារណៈ-ឯកជន, ផ្នែកគ្រប់គ្រងហានិភ័យ
- បង្កើតជាមូលនិធិផ្សេងៗ ដែលអាចកសាងលើគម្រោងមានជោគជ័យស្រាប់
- អនុវត្តការជ្រើសសម្រាំង និងកិច្ចការពារផ្សេងៗ ដើម្បីកាត់បន្ថយផលប៉ះពាល់ដល់សង្គម និងបរិស្ថាន នៃសកម្មភាពគម្រោងដៃគូវិស័យសាធារណៈ-ឯកជន

៤. ទទួលបានធាតុចូលកសិកម្មកាន់តែមានគុណភាពខ្ពស់ និងតម្លៃទាប

- ពង្រឹងច្បាប់គ្រប់គ្រង និងការត្រួតពិនិត្យទីផ្សារជី និងគ្រាប់ពូជ ដើម្បីធានានូវគុណភាពផលិតផល
- ពង្រីកកម្មវិធីចែកចាយគ្រាប់ពូជ ដោយផ្តោតជាពិសេសលើកសិករមានដីតូចៗ
- ពង្រីកដែនគ្របដណ្តប់នៃសេវាឥណទានផ្លូវការ ដើម្បីកាត់បន្ថយបន្ទុកចំណាយលើឥណទាន សម្រាប់កសិករតូចតាច។

៥. ធ្វើពាណិជ្ជកម្ម និងពិពិធកម្មកសិកម្ម

- លើកទឹកចិត្តកសិករតូចតាច ឲ្យដាំដំណាំផ្សេងៗទៀតក្រៅពីស្រូវ ដូចជា ផលិតកម្មកៅស៊ូខ្នាតតូច ការចិញ្ចឹមសត្វជាដើម
- ផ្តល់សេវាមានគុណភាពល្អ ផ្សព្វផ្សាយបច្ចេកទេសកសិកម្ម ដើម្បីបង្កើនប្រសិទ្ធភាពប្រើប្រាស់ និងធ្វើពិពិធកម្មបច្ចេកទេសកសិកម្ម
- ធ្វើឲ្យទីផ្សារកសិកម្មមានលក្ខណៈផ្លូវការ តាមរយៈការបង្កើតស្ថាប័នសម្រាប់ជំរុញឲ្យធាតុចូល និងធាតុចេញមានថ្លៃសមរម្យ និងកែលំអលទ្ធភាពប្រើប្រាស់ទីផ្សារ និងទទួលព័ត៌មានទីផ្សារអាចជឿជាក់បាន ជាពិសេសសម្រាប់កសិករតូចតាច។

៦. បង្កើនជំនាញកម្លាំងពលកម្ម ដើម្បីពង្រឹង និងធ្វើពិពិធកម្មសេដ្ឋកិច្ច

- បង្កើនលទ្ធភាពប្រើប្រាស់ និងពង្រីក កម្មវិធីបណ្តុះបណ្តាល និងអប់រំផ្នែកបច្ចេកទេស និងវិជ្ជាជីវៈ (TVET) ដោយផ្តោតការប្រឹងប្រែងលើ ការកាត់បន្ថយអត្រាគ្មានការងារធ្វើកម្រិតខ្ពស់ក្នុងចំណោមយុវជន
- បំផុសឲ្យអ្នកផ្គត់ផ្គង់ខាងផ្នែកឯកជន មានការចូលរួមកាន់តែប្រសើរក្នុងវិស័យអប់រំ ដើម្បីជំរុញកម្មវិធីសិក្សាផ្សេងៗ ដែលស្របតាមតម្រូវការរបស់វិស័យឯកជន
- ផ្តោតការប្រឹងប្រែងលើការបង្កើនជំនាញកម្លាំងពលកម្ម ដើម្បីឲ្យកម្ពុជាអាចឈានទៅធ្វើផលិតកម្ម ដែលមានតម្លៃបន្ថែមកាន់តែខ្ពស់។

[១] អាទិភាពផ្នែកគោលនយោបាយទាំងនេះ ផ្អែកលើ បទបង្ហាញ និងវគ្គសំណួរចម្លើយនានា នៃសន្និសីទចក្ខុវិស័យប្រទេសកម្ពុជាឆ្នាំ២០១៣។

* លទ្ធផលនៃសន្និសីទចក្ខុវិស័យប្រទេសកម្ពុជា ឆ្នាំ២០១៣
ក្នុងកិច្ចសហការជាដៃគូរវាងវិទ្យាស្ថាន CDRI និង ធនាគារ ANZ Royal

៧. កែលំអស្ថាប័នផ្សេងៗសម្រាប់ការគ្រប់គ្រងដី
- ពង្រឹងច្បាប់គ្រប់គ្រង និងការត្រួតពិនិត្យលើសម្បទានដីសេដ្ឋកិច្ច (ELCs) ដើម្បីទាក់ទាញវិនិយោគិន ដែលជួយជំរុញនូវ កសិ-ឧស្សាហកម្មមានការទទួលខុសត្រូវខ្ពស់ផ្នែកសង្គមកិច្ច និងមានចីរភាពល្អផ្នែកបរិស្ថាន
- ពន្លឿនការបែងចែកឡើងវិញនូវតំបន់ ELC ដែលត្រូវបានលុបចោល ទៅឲ្យប្រជាជនគ្មានដីធ្លី តាមរយៈសម្បទានដីសង្គមកិច្ច (SLCs)
- ធានានូវសិទ្ធិកាន់កាប់ដីធ្លីរបស់ កសិករតូចតាចងាយរងគ្រោះក្នុងទូទាំងប្រទេស តាមការពន្លឿនកម្មវិធីចុះបញ្ជីដីធ្លីថ្នាក់ជាតិ។

៨. ជំរុញការអភិវឌ្ឍសម្រាប់គ្រប់គ្នា
- លើកកម្ពស់សូចនាករផ្នែកសុខភាព លទ្ធភាពទទួលបានសេវាថែទាំសុខភាព និងសំណាញ់សុវត្ថិភាពសង្គម ជាពិសេសសម្រាប់ប្រជាជនក្រីក្រ
- លើកកម្ពស់លទ្ធភាពទទួលបានការអប់រំកម្រិតមធ្យមសិក្សា និងឧត្តមសិក្សា ជាពិសេសសម្រាប់ក្មេងស្រី និងជនក្រីក្រ
- កាត់បន្ថយវិសមភាពក្នុងសង្គម និងគំលាតប្រាក់ចំណូលដែលកំពុងរីកធំឡើង ដើម្បីរក្សាសន្តិភាពសង្គម ស្ថិរភាពសេដ្ឋកិច្ច និងកំណើនមានចីរភាព។

៩. បន្តអនុវត្តគោលនយោបាយ ទាញផលប្រយោជន៍ពីការលូតលាស់នៅអាស៊ី
- រៀបចំរចនាសម្ព័ន្ធសេដ្ឋកិច្ច ដើម្បីចាប់យកឱកាសទីផ្សារផុសចេញថ្មីៗពី អតិថិជននិងឧស្សាហកម្មចិន
- បង្កើនចំណងទាក់ទងក្នុងតំបន់អាស៊ាន ដោយប្រយ័ត្នប្រយែងរក្សាទុកនូវលទ្ធភាពធ្វើគោលនយោបាយក្នុងស្រុក
- កសាងសមត្ថភាពស្ថាប័ន សម្រាប់ពង្រឹងអនុវត្តន៍កិច្ចសន្យា និងដោះស្រាយវិវាទ ដើម្បីបង្កើតបរិយាកាសពាណិជ្ជកម្មអំណោយផលដល់វិនិយោគិនបរទេស។

១០. កែទម្រង់វិស័យហិរញ្ញវត្ថុ ដើម្បីត្រៀមរៀបចំសម្រាប់ការឡើងឋានៈជាប្រទេសមានចំណូលមធ្យម
- បង្កើនឥណទានផ្លូវការដែលមានច្បាប់គ្រប់គ្រង និងការត្រួតពិនិត្យល្អ សម្រាប់សហគ្រាសធុនតូច និងមធ្យម (SMEs) ដើម្បីជំរុញ និងធ្វើពិពិធកម្មកំណើនសេដ្ឋកិច្ច
- បង្កើនតម្លាភាព និងភាពជឿនលឿននៃរបាយការណ៍ហិរញ្ញវត្ថុរបស់ SME ដើម្បីជួយសម្រួលការផ្តល់ឥណទានផ្លូវការ
- ធ្វើឲ្យ SMEs មានលក្ខណៈផ្លូវការ ដើម្បីបង្កើនចំណូលសាធារណៈ និងបង្កើតមូលដ្ឋានយកពន្ធ
- កសាងយុទ្ធសាស្ត្រធ្វើបដិដុល្លារូបនីយកម្មក្នុងសេដ្ឋកិច្ច និងពង្រឹងវិស័យហិរញ្ញវត្ថុ។

**វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (វបសអ/CDRI)**
☞ អគារលេខ ៥៦ ផ្លូវ ៣១៥ ទួលគោក ✉ ប្រអប់សំបុត្រលេខ ៦២២ ភ្នំពេញ កម្ពុជា
☎ (៨៥៥ ២៣) ៨៨១ ៣៨៤, ៨៨១ ៧០១, ៨៨១ ៩១៦, ៨៨៣ ៦០៣ 🖷 (៨៥៥២៣) ៨៨០ ៧៣៤
e-mail: cdri@cdri.org.kh, website: www.cdri.org.kh